ខែកក្កដា 2024

# សៀវភៅណែនាំអំពីសេវាកម្ម

សេវាកម្មផ្សេងៗ | ការកំណត់អត្រាតម្លៃ | ការផ្ញើកញ្ចប់បញ្ញើ | ការទូទាត់វិក្កយបត្រ

ចាប់ផ្ដើម



# មាតិកា

សៀវភៅណែនាំសេវាកម្ម FedEx របស់យើង ផ្ដល់ឲ្យអ្នកនូវរាល់ព័ត៌មានទាំងអស់ដែលអ្នកត្រូវការដើម្បីធ្វើការដឹកជញ្ជូនតាមរយៈ FedEx ។ យើងនឹងណែនាំពន្យល់អ្នកឲ្យយល់អំពីដំណើរការងាយៗដើម្បីទទួលបានជំនួយនិងធនធានដែលអ្នកត្រូវការនៅលើ fedex.com ។


**ទំព័រ 03**
## អំពី FedEx

**ទំព័រ 05**
## របៀបចាប់ផ្ដើម

ចុះឈ្មោះបើកគណនី និងបង្កើតលេខសម្គាល់អ្នកប្រើប្រាស់ fedex.com

មជ្ឈមណ្ឌលអតិថិជនថ្មី

ការក្រឡេកមើលមួយភ្លែតទៅកាន់ fedex.com

**ទំព័រ 09**
## ការដឹកទំនិញតាម FedEx

មុនពេលអ្នកដឹកជញ្ជូនទំនិញ

គ្រប់គ្រងកញ្ចប់បញ្ញើទំនិញរបស់អ្នក

ក្រោយពេលអ្នកដឹកជញ្ជូនទំនិញ

**ទំព័រ 23**
## ទាក់ទងពួកយើង

# អំពី FedEx



# FedEx តភ្ជាប់ពិភពលោក

អរគុណសម្រាប់ការជ្រើសរើសយក FedEx ដែលជាក្រុមហ៊ុនដឹកជញ្ជូនរហ័សដ៏ធំបំផុតរបស់ពិភពលោក។ យើងផ្តល់ការដឹកជញ្ជូនយ៉ាងឆាប់រហ័សនិងអាចទុកចិត្តបានទៅដល់ជាង 220 ប្រទេស និងតំបន់។

យើងភ្ជាប់ទំនាក់ទំនងមនុស្សជាមួយនឹងទំនិញ សេវាកម្ម គំនិតយល់ឃើញ និងបច្ចេកវិទ្យា ដើម្បីបង្កើតឱកាសដែលជំរុញឲ្យមាននវានុវត្តភាព លើកកម្ពស់អាជីវកម្ម និងលើកស្ទួយសហគមន៍ទៅកាន់កម្រិតស្តង់ដារស់នៅខ្ពស់បំផុត។

នៅ FedEx យើងជឿថា នៅពេលពិភពលោកមានទំនាក់ទំនងគ្នានឹងគ្នា នោះវានឹងបង្កើតឱ្យមានពិភពលោកដ៏ល្អត្រកាល ហើយភាពជឿជាក់នេះ នឹងតម្រង់ទិសសម្រាប់អ្វីៗគ្រប់យ៉ាងដែលយើងធ្វើ។

**ស្វែងយល់បន្ថែមអំពី FedEx តាមរយៈ:**
**fedex.com/km-kh/about.html**




**ចំនួនជាតួលេខរបស់ក្រុមហ៊ុនដឹកជញ្ជូនរហ័ស FedEx**

*យន្តហោះដែលមានសរុប រួមទាំងយន្តហោះដែលបានចុះចត។

# របៀបចាប់ផ្តើម

ចុះឈ្មោះបង្កើតគណនី និងបង្កើតលេខសម្គាល់អ្នកប្រើប្រាស់ fedex.com

មជ្ឈមណ្ឌលអតិថិជនថ្មី

ការក្រឡេកមើលមួយភ្លែតទៅកាន់ fedex.com



# ចាប់ផ្តើមដោយ ចុះឈ្មោះបង្កើតគណនីដឹកជញ្ជូន FedEx

ចុះឈ្មោះបើកគណនីដឹកជញ្ជូន FedEx នៅពេលនេះ និងប្រើប្រាស់អត្ថប្រយោជន៍នៃសេវាកម្មនិងដំណោះស្រាយនានារបស់យើង ដើម្បីបំពេញតាមតម្រូវការដឹកជញ្ជូនទាំងអស់របស់អ្នក។



## ជំហានទី 1៖ សូមបើកគណនីក្រុមហ៊ុន

**គណនីក្រុមហ៊ុន**

ជ្រើសរើសរវាងគណនីក្រុមហ៊ុនមួយដែលមានរយៈពេលឥណទាន 30 ថ្ងៃតាមស្តង់ដា ឬការបង់ប្រាក់តាមរយៈប័ណ្ណឥណទានដែលមានសុពលភាព។

**បើកគណនី**

## ជំហានទី 2៖ បង្កើតលេខសម្គាល់អ្នកប្រើប្រាស់ fedex.com

នៅពេលអ្នកចុះឈ្មោះបង្កើតគណនីថ្មីមួយ សូមចាំថាត្រូវបង្កើតលេខសម្គាល់អ្នកប្រើប្រាស់ fedex.com ដើម្បីឲ្យអ្នកអាចគ្រប់គ្រងកញ្ចប់បញ្ញើទំនិញរបស់អ្នកតាមអនឡាញបាន និង ទទួលបានជំនួយភ្លាមៗពីពួកយើង។

**បង្កើតលេខសម្គាល់អ្នកប្រើប្រាស់ FEDEX.COM**



# មជ្ឈមណ្ឌលអតិថិជនថ្មីរបស់យើងតែងបើកដំណើរការជានិច្ច

អ្នកមិនចាំបាច់ត្រូវបារម្ភអំពីកន្លែងដែលអ្នកត្រូវចាប់ផ្តើមនោះទេ។ មជ្ឈមណ្ឌលអតិថិជនថ្មីរបស់យើងនៅក្នុង fedex.com ណែនាំពន្យល់អ្នកឲ្យយល់គ្រប់ជំហាន —ចាប់ផ្តើមពីការដឹកជញ្ជូនលើកដំបូងរបស់អ្នក រហូតដល់គ្រប់យ៉ាងដែលអ្នកចង់ធ្វើសម្រាប់ការដឹកជញ្ជូននាពេលអនាគត។

ចូលទៅកាន់មជ្ឈមណ្ឌលអតិថិជនថ្មីរបស់យើង និងបង្កើតបែបផែនផ្ទាល់ខ្លួនអ្នកសម្រាប់ការដឹកជញ្ជូនតាមរយៈ FedEx ។

fedex.com/km-kh/new-customer.html

# ទទួលបានធនធាននៃការដឹកជញ្ជូនភ្លាមៗតាមរយៈ fedex.com

មធ្យោបាយផ្ដាច់មុខដើម្បីឲ្យការដឹកជញ្ជូនរបស់អ្នកកាន់តែមានភាពងាយស្រួល គឺចូលទៅកាន់ fedex.com ។ ធ្វើសេវាកម្មដោយខ្លួនឯងតាមរយៈឧបករណ៍អនឡាញទំនើបឈានមុខគេរបស់យើង និងទទួលបានព័ត៌មានលម្អិតនិងគន្លឹះណែនាំដ៏មានប្រយោជន៍ដើម្បីជួយអ្នកទៅលើអាជីវកម្ម និងតម្រូវការដឹកជញ្ជូនរបស់អ្នក។





សេវាកម្មរបស់យើង ទំព័រ 10

ទទួលបានអត្រាតម្លៃ និងរយៈពេលដឹកជញ្ជូនទំនិញ ទំព័រ 12

ការផ្ញើកញ្ចប់បញ្ញើតាមអនឡាញ ទំព័រ 13

កញ្ចប់ទំនិញ ទំព័រ 17

ការតាមដាន ទំព័រ 20

ការចេញវិក្កយបត្រទូទាត់ ទំព័រ 22

# ការដឹកទំនិញតាម FedEx

មុនពេលអ្នកដឹកជញ្ជូនទំនិញ

គ្រប់គ្រងកញ្ចប់បញ្ញើទំនិញរបស់អ្នក

ក្រោយពេលអ្នកដឹកជញ្ជូនទំនិញ



ចុចលើឈ្មោះសេវាកម្មដើម្បីពិនិត្យមើលព័ត៌មានលម្អិត។

# បញ្ជូនកញ្ចប់បញ្ញើទំនិញរបស់អ្នក ទៅកាន់ 220 ប្រទេស និងតំបន់ដោយប្រើសេវាកម្មដ៏សម្បូរបែបរបស់យើង

ជ្រើសរើសសេវាកម្មដឹកជញ្ជូនដ៏ល្អបំផុតផ្អែកលើអាទិភាពចម្បងបំផុតរបស់អ្នក មិនថាអ្នកចង់ផ្តោតទៅលើល្បឿន ថវិកា ឬក៏ដំណោះស្រាយតាមការចង់បានរបស់បុគ្គល។

**មើលរាល់សេវាកម្មទាំងអស់**



| ទម្ងន់ក្នុងមួយកញ្ចប់ទំនិញ | ខ្ញុំចង់បានការដឹកជញ្ជូនកញ្ចប់បញ្ញើដែលលឿនជាងគេបំផុត | ខ្ញុំចង់បានការដឹកជញ្ជូនដែលចំណាយថវិកាតិច |
|---|---|---|
| < 68 គ.ក | FedEx International First®<br>FedEx International Priority® | |
| > 68 គ.ក | FedEx International Priority® Freight | |
| >300 គ.ក | ក្រុមការងារផ្នែកសេវាកម្មអតិថិជនរបស់យើងអាចជួយអ្នកឲ្យទទួលបានរយៈពេលដឹកជញ្ជូនកញ្ចប់បញ្ញើទំនិញមកពី/ទៅកាន់ ប្រភពដើម/ទិសដៅផ្សេងៗគ្នា និងសម្រាប់ការកក់កញ្ចប់បញ្ញើទំនិញណាមួយ > ទម្ងន់ 300 គ.ក។<br>**ទាក់ទងមកយើងតាមរយៈ**: fedex.com/km-kh/customer-support.html | |

មើលលក្ខខណ្ឌស្តង់ដានៃការដឹកជញ្ជូន សម្រាប់លក្ខខណ្ឌពេញលេញដែលគ្រប់គ្រងសេវាកម្ម FedEx តាមរយៈ:
**www.fedex.com/km-kh/conditions-of-carriage.html**




# សេវាកម្ម FedEx International Priority®

**FedEx International First®**
ការបញ្ជូនទំនិញទាន់ពេល នឹងតាមពេលវេលាកំណត់ដែលទំនិញនឹងមកដល់ ជាមួយនឹងការបញ្ចេញទំនិញពីគយ ដឹកទំនិញដល់គេហដ្ឋាន ទៅ/មកពីទ្វីបអាមេរិកខាងជើង (រយៈពេលពី 1 ថ្ងៃ ទៅ 3 ថ្ងៃនៃថ្ងៃធ្វើការ)

**FedEx International Priority®**
ការដឹកជញ្ជូនដល់គេហដ្ឋាននៅថ្ងៃធ្វើការបន្ទាប់ នៅពេលចប់ម៉ោងការងារ (រយៈពេលពី 1 ថ្ងៃដល់ 3 ថ្ងៃនៃថ្ងៃធ្វើការ)

**FedEx International Priority® Freight**
សេវាកម្មដឹកជញ្ជូនផ្លូវអាកាសលំដាប់ពិសេសឈានមុខគេ ឆាប់រហ័ស និងអាចទុកចិត្តបានសម្រាប់ទម្ងន់អប្បបរមា 68 គ.ក។
(រយៈពេលពី 1 ថ្ងៃដល់ 3 ថ្ងៃនៃថ្ងៃធ្វើការ)

**មើលព័ត៌មានលម្អិតអំពីលក្ខណៈពិសេសនៃសេវាកម្មតាមរយៈ: fedex.com/km-kh/shipping.html#priorityservices**

# ត្រូវការសម្រង់តម្លៃ និងរយៈពេលដឹកជញ្ជូនទំនិញនៅពេលនេះមែនទេ?

បញ្ចូលព័ត៌មានមូលដ្ឋានមួយចំនួនអំពីកញ្ចប់បញ្ញើទំនិញរបស់អ្នកនៅក្នុងឧបករណ៍កំណត់អត្រាតម្លៃតាមរយៈ fedex.com ហើយអ្នកនឹងទទួលបានសម្រង់តម្លៃ និងរយៈពេលដឹកជញ្ជូនទំនិញភ្លាមៗ។

**នេះគឺជាជំហានទាំង 3 ក្នុងការប្រើប្រាស់ឧបករណ៍កំណត់តម្លៃតាមអនឡាញ៖**

1 បញ្ចូលប្រភពដើម និងទីតាំងទិសដៅ។

2 ជ្រើសរើសប្រភេទកញ្ចប់ទំនិញ និងចំនួនកញ្ចប់ទំនិញ

3 ជ្រើសរើសទម្ងន់ វិមាត្រ កាលបរិច្ឆេទដឹកជញ្ជូន ហើយបញ្ជូន

**ទទួលបានអត្រាតម្លៃនិងរយៈពេលដឹកជញ្ជូនទំនិញតាមរយៈ: fedex.com/km-kh/online/rating.html**

* ចូលទៅកាន់គណនីរបស់អ្នក ដើម្បីមើលអត្រាតម្លៃជាក់លាក់នៃគណនី និងសេវាកម្មផ្សេងៗ។
** អត្រាតម្លៃដែលបានបង្ហាញ អាចនឹងខុសពីការគិតថ្លៃជាក់ស្តែង។

### អត្រាតម្លៃនៃការដឹកទំនិញរបស់ FedEx
មើលនិងទាញយកឯកសារជាទម្រង់ PDF នៃអត្រាតម្លៃដឹកជញ្ជូនទំនិញ FedEx នៅលើ fedex.com/km-kh/shipping/rates.html

### ថ្លៃប្រេងឥន្ធនៈអន្តរជាតិ
ពិនិត្យមើលការកែតម្រូវភាគរយនៃការគិតថ្លៃប្រេងឥន្ធនៈបន្ថែមសម្រាប់សេវាកម្ម FedEx Express® តាមរយៈ: fedex.com/km-kh/shipping/surcharges.html

### តម្លៃបន្ថែមផ្សេងទៀត
សម្រាប់អ្នកបង់ប្រាក់ សូមទាញយក ‘ព័ត៌មានស្តីពីការគិតថ្លៃបន្ថែម FedEx និងព័ត៌មានផ្សេងៗ’ តាមរយៈ: fedex.com/km-kh/shipping/surcharges/other-surcharges.html





# ដឹកជញ្ជូនតាមអនឡាញតាមរយៈ fedex.com – ជាមធ្យោបាយដ៏ឆាប់រហ័សបំផុតក្នុងការបង្កើតកញ្ចប់បញ្ញើទំនិញរបស់អ្នក

អ្នកអាចបង្កើតកញ្ចប់បញ្ញើទំនិញ កំណត់ពេលទៅយកទំនិញ បោះពុម្ពអញ្ញត្តិបណ្ណផ្លូវអាកាស និងអ្វីៗជាច្រើនទៀតតាមរយៈ fedex.com ។ ចូលទៅកាន់ fedex.com/km-kh/online/shipping.html និងបញ្ចូលព័ត៌មានអំពីអ្នកទទួលនិងកញ្ចប់ទំនិញ និងជ្រើសរើសប្រភេទសេវាកម្ម និងជម្រើសទូទាត់វិក្កយបត្រ។

**ចាប់ផ្តើមការដឹកជញ្ជូនតាមអនឡាញដោយអនុវត្តតាមជំហានងាយៗដូចខាងក្រោម៖**

1 **បើកគណនី FedEx**

2 **បង្កើតលេខសម្គាល់អ្នកប្រើប្រាស់ fedex.com របស់អ្នក**

3 **ចូលប្រើ ហើយចុចដឹកជញ្ជូននៅពេលនេះ!**

**សៀវភៅជំនួយគឺមានផ្តល់ជូនតាមរយៈ: fedex.com/km-kh/online/shipping/help.html**





# ដឹកជញ្ជូនតាមអនឡាញតាមកម្មវិធី FedEx Ship Manager™ តាមរយៈ fedex.com

ទទួលបានប្រសិទ្ធភាពសម្រាប់អាជីវកម្មរបស់អ្នកតាមរយៈដំណោះស្រាយដឹកជញ្ជូនតាមអនឡាញរបស់យើង – FedEx Ship Manager™ នៅលើ fedex.com ។

**រីករាយជាមួយនឹងអត្ថប្រយោជន៍ដូចខាងក្រោម៖**

ទទួលបានអត្រាតម្លៃ និងរយៈពេលដឹកជញ្ជូនទំនិញយ៉ាងឆាប់រហ័សនិងងាយស្រួល

កំណត់ពេលទៅយកទំនិញដោយមិនបាច់ហៅទូរស័ព្ទឡើយ

ទទួលបានទិដ្ឋភាពពេញលេញទៅលើស្ថានភាពកញ្ចប់បញ្ញើទំនិញរបស់អ្នក

សន្សំសំចៃពេលវេលាក្នុងការរៀបចំកញ្ចប់បញ្ញើទំនិញ

បង្កើតឯកសារការបញ្ចេញទំនិញពីគយបានយ៉ាងងាយស្រួល

មើលអត្ថប្រយោជន៍ទាំងអស់

ទាញយកឯកសារអំពីការណែនាំសម្រាប់អ្នកប្រើប្រាស់



ស្វែងយល់ពីរបៀបបង្កើតកញ្ចប់បញ្ញើទំនិញតាមអនឡាញ។ មើលវីដេអូ

# ការរៀបចំឯកសារបញ្ចេញទំនិញពីគយមានភាពងាយស្រួល

លែងមានការពិបាកក្នុងការរៀបចំឯកសារបញ្ចេញទំនិញពីគយរបស់អ្នកទៀតហើយ!

Global Trade Manager គឺជាប្រភពឯកសារគ្រប់ប្រភេទនៅកន្លែងតែមួយសម្រាប់ព័ត៌មានដឹកជញ្ជូនអន្តរជាតិ និងលក្ខខណ្ឌតម្រូវនៃឯកសារបញ្ចេញទំនិញពីគយ។ អ្នកអាចផ្តល់ទម្រង់បែបបទសម្រាប់ផ្ញើទំនិញរបស់អ្នក និងមើលថាតើទម្រង់បែបបទនិងព័ត៌មានអ្វីខ្លះដែលអ្នកចាំបាច់ត្រូវបំពេញ ឬប្រគល់។

**Global Trade Manager ផ្តល់ជូនជាអាទិ៍ដូចខាងក្រោម។**

ប៉ាន់ស្មានពន្ធគយ និងអាករ

ទទួលបានជំនួយក្នុងការស្វែងរកឯកសារចាំបាច់

ទទួលបានព័ត៌មាននិយ័តកម្មសំខាន់ជាក់លាក់ចំពោះកញ្ចប់បញ្ញើទំនិញរបស់អ្នក

**មើលព័ត៌មានលម្អិតនៃឧបករណ៍ទាក់ទងនឹងគយនៅលើ fedex.com/km-kh/customs-tools.html**

**មើល Global Trade Manager នៅលើ fedex.com/GTM?cntry_code=kh**

**ស្វែងយល់ពីរបៀបបំពេញវិក្កយបត្រពាណិជ្ជកម្ម**





# ផ្ញើឯកសារពាណិជ្ជកម្មរបស់អ្នកតាមអនឡាញ និង រីករាយដោយគ្មានការបារម្ភ

អ្នកអាចអាប់ឡូដ និងប្រគល់ឯកសារពាណិជ្ជកម្មរបស់អ្នកតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈកម្មវិធី FedEx® Electronic Trade Documents ។ ដំណោះស្រាយដ៏សាមញ្ញ មានប្រសិទ្ធភាព និងអាចទុកចិត្តបាននេះ កាត់បន្ថយការពន្យារពេលនៅផ្នែកគយ និងធានាបាននូវការប្រគល់កញ្ចប់ទំនិញក្រៅប្រទេសរបស់អ្នកតាមពេលកំណត់។

**ចាប់ផ្តើមបើកដំណើរការការអាប់ឡូដតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈឧបករណ៍ដូចខាងក្រោម។**

**កម្មវិធី FedEx Ship Manager™ នៅលើ fedex.com**
**កម្មវិធី FedEx Ship Manager™**
**សេវាកម្មបណ្ដាញ FedEx**

**មានវិធីបីយ៉ាងក្នុងការអាប់ឡូដឯកសារពាណិជ្ជកម្មតាមរយៈកម្មវិធី FedEx Electronic Trade Documents*៖**

ផ្លាស់មៅស៍របស់អ្នកទៅលើឈ្មោះសេវាកម្ម ដើម្បីមើលឃើញការពិពណ៌នា។

**មុនពេលដឹកជញ្ជូន**

**ពេលដឹកជញ្ជូន**

**ក្រោយពេលដឹកជញ្ជូន**

*ជម្រើសដែលមាន អាចនឹងប្រែប្រួលអាស្រ័យលើទីតាំងទិសដៅ។

# ស្វែងរកកញ្ចប់ដែលល្អបំផុតសម្រាប់កញ្ចប់បញ្ញើទំនិញរបស់អ្នក

ការវេចខ្ចប់ត្រឹមត្រូវធានាថា ការដឹកជញ្ជូនរបស់អ្នកអាចមកដល់ដោយសុវត្ថិភាពដូចស្ថានភាពដែលវាទើបបានផ្ញើមក។ យើងបានបង្កើតនូវកញ្ចប់វេចខ្ចប់ជាច្រើនដែលងាយស្រួលប្រើប្រាស់និងបិទភ្ជិតបានដោយខ្លួនឯង ក្នុងរូបរាងនិងទំហំផ្សេងៗគ្នា។ រាល់ការរចនានីមួយៗត្រូវបានបញ្ជាក់ច្រើនលើក ច្រើនសា រាប់លានដង។

ផ្លាស់ទីមៅស៍របស់អ្នកទៅលើរូបភាពនៃសម្ភារៈផ្គត់ផ្គង់ ដើម្បីមើលឃើញឧទាហរណ៍អំពីមុខទំនិញដែលអាចដឹកជញ្ជូនបាន។

**ជ្រើសរើសចេញមកពីសម្ភារៈផ្គត់ផ្គង់ជាច្រើនរបស់ FedEx ហើយបញ្ជាទិញវានៅលើ [fedex.com/km-kh/shipping/packaging/supplies.html](fedex.com/km-kh/shipping/packaging/supplies.html)**

## ស្រោមសំបុត្រ

ឯកសារទំហំ Letter និង Legal




**ស្រោមសំបុត្រ**
9.252” x 13.189”
(23.5 ស.ម x 33.5 ស.ម)

## កញ្ចប់

កញ្ចប់វេចខ្ចប់ធន់នឹងការរហែក ហើយធន់នឹងទឹក




**កញ្ចប់ធំដែលអាចប្រើឡើងវិញបាន**
12” x 15.5”
(30.48 ស.ម x 39.37 ស.ម)




**កញ្ចប់ Pak ធំបន្ថែម ដែលអាចប្រើឡើងវិញបាន**
17.5” x 20.75“
(44.45 ស.ម x 52.71 ស.ម)

## ប្រអប់

ប្រអប់រឹងមាំដែលមានច្រើនទំហំ




**ប្រអប់តូច**
12.25” x 10.9” x 1.5“
(31.12 ស.ម x 27.69 ស.ម x 3.81 ស.ម)




**ប្រអប់មធ្យម**
13.25” x 11.5” x 2.38“
(33.66 ស.ម x 29.21 ស.ម x 6.03 ស.ម)




**ប្រអប់ធំ**
17.88” x 12.38” x 3“
(45.40 ស.ម x 31.43 ស.ម x 7.62 ស.ម)

## បំពង់

- ប្រអប់រាងត្រីកោណសម្រាប់គម្រោងផែនការ ផ្ទាំងរូបភាព ដុំក្រណាត់ គំនូសតាង និងប្លង់មេ។




**បំពង់**
38” x 6” x 6” x 6”
(96.52 ស.ម x 15.24 ស.ម x 15.24 ស.ម x 15.24 ស.ម)

## ប្រអប់ 10 គ.ក / 25 គ.ក

ប្រអប់រឹងបន្ថែមទៀតសម្រាប់កញ្ចប់បញ្ញើទំនិញធំនិងធ្ងន់ជាងនេះ




**ប្រអប់ 10 គ.ក**
15.81” x 12.94” x 10.19“
(40.16 ស.ម x 32.86 ស.ម x 25.88 ស.ម)




**ប្រអប់ 25 គ.ក**
21.56” x 16.56” x 13.19“
(54.8 ស.ម x 42.1 ស.ម x 33.5 ស.ម)

# វេចខ្ចប់កញ្ចប់បញ្ញើទំនិញរបស់អ្នកនៅក្នុងកញ្ចប់វេចខ្ចប់ផ្ទាល់ខ្លួនរបស់អ្នក

អ្នកអាចជ្រើសរើសប្រើប្រាស់កញ្ចប់វេចខ្ចប់ផ្ទាល់ខ្លួនរបស់អ្នកដោយយោងទៅលើគោលការណ៍ណែនាំខាងក្រោម។



សម្រាប់កញ្ចប់បញ្ញើទំនិញទម្ងន់ស្រាលទំហំធំ ការគិតប្រាក់នឹងគិតទៅតាមទម្ងន់មួយណាដែលធំជាងគេ អាចជាទម្ងន់តាមវិមាត្រ (ទម្ងន់បរិមាណ) ឬទម្ងន់ជាក់ស្ដែង។
ការកំណត់តម្លៃទម្ងន់តាមវិមាត្រ អាចអនុវត្តបានផ្អែកលើមូលដ្ឋានកញ្ចប់ទំនិញក្នុងមួយកញ្ចប់ ចំពោះរាល់កញ្ចប់បញ្ញើទំនិញទាំងអស់នៅក្នុងកញ្ចប់វេចខ្ចប់ផ្ទាល់ខ្លួនរបស់អតិថិជន និងកញ្ចប់បញ្ញើទំនិញ FedEx Pak ដែលលើសពី 940 អ៊ិញគូប ឬ 15,403 សង់ទីម៉ែត្រគូប។

# គន្លឹះណែនាំអំពីការវេចខ្ចប់

*អាចនឹងប្រែប្រួលតាមទីតាំងទិសដៅ
**លក្ខខណ្ឌត្រូវបានអនុវត្ត

| ទម្ងន់ក្នុងមួយកញ្ចប់ទំនិញ | ប្រវែងក្នុងមួយកញ្ចប់ទំនិញ | បណ្ដោយ + បរិមាត្រ | តម្លៃប្រតិវេទន៍អតិបរមា |
|---|---|---|---|
| ≤ | ≤ | ≤ | ≤ |
| 68 គ.ក/150lb* | 274 ស.ម* | 330 ស.ម* | 50,000 US$ |

# ការគណនា (រូបមន្ត) ទម្ងន់តាមវិមាត្រ




**សង់ទីម៉ែត្រ (ស.ម)**

បណ្ដោយ x ទទឹង x កម្ពស់
5000

**អ៊ិញ (in)**

បណ្ដោយ x ទទឹង x កម្ពស់
305

បណ្ដោយ៖ ជ្រុងដែលវែងបំផុត
បរិមាត្រ៖ (កម្ពស់ + ទទឹង) * 2

ទាក់ទងទៅកាន់ ផ្នែកជំនួយអតិថិជន ដើម្បីទទួលបានសម្រង់តម្លៃ និងគន្លឹះណែនាំអំពីការវេចខ្ចប់សម្រាប់កញ្ចប់បញ្ញើទំនិញដែលធំលើសទំហំធម្មតា។



# ត្រៀមផ្ញើកញ្ចប់ទំនិញរបស់អ្នករួចរាល់ហើយឬនៅ? កំណត់ពេលទទួលយកទំនិញ យ៉ាងឆាប់រហ័សបំផុតដោយប្រើចុងម្រាមដៃរបស់អ្នក

នៅពេលអ្នកបានបញ្ចប់ការវេចខ្ចប់និងសំណុំឯកសាររបស់អ្នករួចរាល់ ហើយកញ្ចប់បញ្ញើទំនិញរបស់អ្នកត្រៀមរួចរាល់ក្នុងការចេញដំណើរ នោះអ្នកអាចកំណត់ពេលទៅយកទំនិញដោយផ្ទាល់តាមអនឡាញ ឬដោយទូរស័ព្ទទៅកាន់ផ្នែកសេវាបម្រើអតិថិជន។

**រៀបចំការទៅយកទំនិញតាមអនឡាញ**

**កំណត់ពេលវេលាទៅយកទំនិញតាមអនឡាញ**
អ្នកអាចកំណត់ពេល មើល កែប្រែ ឬលុបចោលសំណើទៅយកទំនិញតាមអនឡាញដោយគ្រាន់តែចុចពីរបីដងប៉ុណ្ណោះ។

**កម្មវិធី FedEx Ship Manager™ នៅលើ fedex.com**
បន្ថែមទីតាំងទៅយកទំនិញថ្មីៗទៅក្នុងសៀវភៅអាសយដ្ឋាននៃកម្មវិធី FedEx Ship Manager™ របស់អ្នកដោយផ្ទាល់។

**កំណត់ពេលទៅយកទំនិញតាមទូរស័ព្ទ**
ទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទបន្ទាន់សម្រាប់សេវាបម្រើអតិថិជន ដើម្បីរៀបចំការទៅយកទំនិញ។

សម្រាប់អ្នកភ្ជាប់ PLDT, Sun, Smart លេខ +855 23 923 339
សម្រាប់អ្នកភ្ជាប់ Globe លេខ +855 23 923 339
អ្នកភ្ជាប់បណ្ដាញផ្សេងទៀត លេខ +855 23 923 339

# តាមដានការដឹកជញ្ជូនកញ្ចប់បញ្ញើទៅតាមចំណង់ចំណូលចិត្តរបស់លោកអ្នក

ឧបករណ៍តាមដានតាមអនឡាញ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ផ្តល់ឲ្យអ្នកនូវការគ្រប់គ្រងទៅលើកញ្ចប់បញ្ញើទំនិញរបស់អ្នក។ មិនថាវាជាកញ្ចប់ទំនិញតែមួយឬច្រើនមុខនោះទេ ឬមិនថាអ្នកប្រើប្រាស់កុំព្យូទ័រលើតុ ឬ ទូរស័ព្ទចល័តនោះទេ អ្នកអាចមើលស្ថានភាពកញ្ចប់បញ្ញើទំនិញរបស់អ្នក ឬទទួលបានភស្តុតាងនៃការដឹកប្រគល់ទំនិញ រហូតដល់ 30 កញ្ចប់។

**តើអ្នកមានលេខតាមដាន ឬត្រូវការភស្តុតាងនៃការដឹកប្រគល់ទំនិញសម្រាប់ កញ្ចប់បញ្ញើទំនិញរបស់អ្នកដែរឬទេ?**
អ្នកអាចបញ្ចូលព័ត៌មានណាមួយខាងលើ ដោយប្រើឧបករណ៍ដូចខាងក្រោម។

**ស្វែងយល់បន្ថែមអំពីការតាមដានតាមរយៈ: fedex.com/km-kh/tracking.html**

### តាមដានកញ្ចប់បញ្ញើទំនិញដោយមិនចាំបាច់ចុះឈ្មោះចូល

បញ្ចូលលេខតាមដាន ឬលេខយោងដើម្បីទទួលបានស្ថានភាពកញ្ចប់បញ្ញើទំនិញរបស់អ្នកនិងទទួលបានភស្តុតាងនៃការដឹកប្រគល់ទំនិញតាមរយៈ fedex.com ។

### តាមដានកញ្ចប់បញ្ញើទំនិញដោយការចុះឈ្មោះចូល

សម្រាប់កញ្ចប់បញ្ញើដែលដឹកជញ្ជូនតាមកម្មវិធី FedEx Ship Manager™ នៅលើ fedex.com លទ្ធផលនៃការតាមដាន និងព័ត៌មានលម្អិតនឹងបង្ហាញដោយស្វ័យប្រវត្តិបន្ទាប់ពីអ្នកចូលប្រើ។

### កម្មវិធីតាមដានទំនិញលើទូរស័ព្ទរបស់ FedEx

ការតាមដានទំនិញលើទូរស័ព្ទរបស់ FedEx គឺជាឧបករណ៍តាមដានដ៏ងាយស្រួលបំផុតរបស់យើង ដោយផ្តល់ឲ្យអ្នកនូវព័ត៌មានថ្មីៗនៅពេលអ្នកកំពុងធ្វើដំណើរតាមផ្លូវ ដើម្បីឲ្យអ្នកអាចបន្តត្រួតពិនិត្យកញ្ចប់បញ្ញើទំនិញរបស់អ្នក 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ និងពីទីកន្លែងណាមួយក៏បាន។



# ធ្វើឱ្យការប្រគល់ទំនិញកាន់ងាយស្រួលសម្រាប់អតិថិជនរបស់អ្នកតាមរយៈ FedEx® Delivery Manager

តាមរយៈ FedEx® Delivery Manager អ្នកអាចផ្តល់ជូនអតិថិជនរបស់អ្នកនូវសមត្ថភាពក្នុងការកំណត់កាលបរិច្ឆេទ និងទីតាំងនៃការដឹកជញ្ជូនទៅដល់គោលដៅតាមបំណងរបស់ពួកគេ ដោយឥតគិតថ្លៃបន្ថែម។ ដោយគ្រាន់តែបើកដំណើរការជម្រើសនៃការជូនដំណឹង នៅពេលប្រើប្រាស់ឧបករណ៍អនឡាញណាមួយរបស់ FedEx ដូចជា FedEx Ship Manager™ នោះអតិថិជនរបស់អ្នកអាចរីករាយនឹងជម្រើសនៃការដឹកជញ្ជូនទំនិញជាច្រើនបាន។

**ជម្រើសនៃការដឹកជញ្ជូនទំនិញដែលមាន***

- ប្រគល់ទំនិញតាមផែនការកំណត់
- ប្រគល់ទំនិញតាមផែនការទៅទីកន្លែងសុវត្ថិភាព
- ប្រគល់ទំនិញទៅអាសយដ្ឋានរបស់ខ្ញុំនៅថ្ងៃអនាគត
- ប្រគល់ទំនិញទៅដល់អ្នកជិតខាង
- ប្រគល់ទំនិញទៅអាសយដ្ឋានផ្សេងទៀត
- ប្រគល់ទំនិញទៅទីតាំងទទួលទំនិញ

*ជម្រើសដែលមាន អាចនឹងប្រែប្រួលអាស្រ័យលើប្រទេស/តំបន់ទីតាំងទិសដៅ។




**ស្វែងយល់អំពីអត្ថប្រយោជន៍សម្រាប់ទាំងអតិថិជនរបស់អ្នក និងអាជីវកម្មរបស់អ្នកតាមរយៈ: [fedex.com/km-kh/shipping-tools/deliverymanager.html](fedex.com/km-kh/shipping-tools/deliverymanager.html)**

# វិធីងាយស្រួលបំផុតដើម្បីគ្រប់គ្រងវិក្កយបត្ររបស់អ្នក។

នៅពេលនេះអ្នកអាចទទួលបានវិក្កយបត្ររបស់អ្នកតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ FedEx® Billing Online និងរីករាយជាមួយនឹងជម្រើសទូទាត់វិក្កយបត្រជាច្រើនជម្រើសដែលផ្តល់ជូនដល់អាជីវកម្មរបស់អ្នក។ អ្នកអាចមើល ទាញយក និងបោះពុម្ពរាល់វិក្កយបត្រ ឬសំណុំឯកសារគយ និងទូទាត់ពួកវាតាមអនឡាញ ដោយគ្រាន់តែចុចតែមួយដងប៉ុណ្ណោះ។

**ចុះឈ្មោះសម្រាប់ FedEx Billing Online**

**ទាញយកឯកសារអំពីការណែនាំសម្រាប់អ្នកប្រើប្រាស់**

**ស្វែងយល់អំពីអត្ថប្រយោជន៍អាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ:**
**fedex.com/km-kh/billing.html**



# ជ្រើសរើសវិធីសាស្រ្តបង់ប្រាក់ដែលសមស្របបំផុត

ដើម្បីជាការងាយស្រួលសម្រាប់អ្នក មានមធ្យោបាយជាច្រើនសម្រាប់ឲ្យអ្នកជ្រើសរើសទូទាត់វិក្កយបត្ររបស់អ្នក។ ដើម្បីទទួលបានការណែនាំអំពីមធ្យោបាយនីមួយៗក្នុងការចាត់ចែងការទូទាត់របស់អ្នក សូមចូលទៅកាន់ fedex.com/km-kh/billing.html និងជ្រើសរើសវិធីសាស្រ្តដ៏ល្អបំផុតសម្រាប់ស្ថានភាពរបស់អ្នក។

### ការផ្ទេរប្រាក់

វាគឺជាជម្រើសដ៏ល្អបំផុតប្រសិនបើអ្នកចង់មានភាពងាយស្រួលសម្រាប់កិច្ចដំណើរការបង់ប្រាក់។

**ជម្រើសរបស់អ្នក៖**
ការផ្ទេរប្រាក់
ការទូទាត់សាច់ប្រាក់
ការទូទាត់មូលប្បទានប័ត្រ

**ស្វែងយល់បន្ថែមតាមរយៈ:**
**fedex.com/km-kh/billing.html**

### កាតឥណទាន និងប័ណ្ណឥណទាន

មធ្យោបាយកាន់តែងាយស្រួលនៃការបង់ប្រាក់ គឺតាមរយៈកាតឥណទាន។

**ជម្រើសរបស់អ្នក៖**
FedEx® Billing Online
ប័ណ្ណឥណទាន

# សូមទាក់ទងមកកាន់យើងខ្ញុំ





# ក្រុមជំនាញផ្នែកជំនួយអតិថិជនរបស់យើងនៅទីនេះសម្រាប់អ្នក។

យើងបើកចំហក្នុងការទទួលយកព័ត៌មានអំពីតម្រូវការរបស់អ្នកសម្រាប់ការដឹកជញ្ជូនជាមួយពួកយើង។ ក្រុមផ្នែកជំនួយអតិថិជនរបស់យើងអាចផ្តល់ឲ្យអ្នកនូវជំនួយពេញលេញទៅលើសំណើរបស់អ្នកតាមរយៈ ឆាត អ៊ីមែល សារ ឬខ្សែទូរស័ព្ទបន្ទាន់។

**ដើម្បីស្វែងយល់អំពីរបៀបទទួលបានជំនួយផ្នែកបច្ចេកទេស សំណួរដែលសួរញឹកញាប់ ឬរបៀបដាក់ពាក្យបណ្តឹងទាមទារ សូមចូលទៅកាន់ផ្នែកសេវាបម្រើអតិថិជនតាមរយៈ: fedex.com/km-kh/customer-support.html**

## សំណួរទូទៅ

លេខទូរសព្ទរបស់យើងខ្ញុំ ។

ទម្រង់បែបបទទំនាក់ទំនងតាមអនឡាញ

អ៊ីមែលសម្រាប់សំណួរទូទៅ

## ជំនួយបច្ចេកទេស

**ផលិតផលនិងកម្មវិធីស្វ័យប្រវត្តិ FedEx ៖**
ខ្សែទូរស័ព្ទឥតគិតថ្លៃ PLDT **1800.1441.0830**
ខ្សែទូរស័ព្ទឥតគិតថ្លៃរបស់ Globe **1800.8908.6579**

**ម៉ោងសេវាកម្ម៖**
ច័ន្ទ-សុក្រ៖ ម៉ោង 0800 ដល់ 1800
(មានជាភាសាអង់គ្លេស)

អ៊ីមែលសម្រាប់ជំនួយបច្ចេកទេស